សាលាដំបូងខេត្តបាត់ដំបង
សំណុំរឿងព្រហ្មទណ្ឌ
លេខ៖១២២៨/២៨-១០-២០
សំណុំរឿងជំនុំជម្រះ
លេខ៖ ០៤/០៥-០១-២១
សាលក្រមព្រហ្មទណ្ឌ
លេខ៖៤៨"ក"/១៨-០១-២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# នាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តបាត់ដំបង នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ ត្រូវនឹងថ្ងៃពុធ ១៥ រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព-ស ២៥៦៤ ប្រកាសជាសាធារណៈ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ ២០២១ ត្រូវនឹងថ្ងៃច័ន្ទ ៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព-ស ២៥៦៤ ដែលមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តបាត់ដំបង

**តំណាងអយ្យការ**

ឯកឧត្តម [redacted] ព្រះរាជអាជ្ញា
នៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តបាត់ដំបង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១២២៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ ៖

១-ឈ្មោះ [redacted]វដ្ឋា ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅភូមិ[redacted] ខេត្តបាត់ដំបង សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ មានទីលំនៅបច្ចុប្បន្ន ភូមិ[redacted] ខេត្តបាត់ដំបង ពោះម៉ាយ មានកូនចំនួន០១នាក់ ឪពុកឈ្មោះ [redacted] ធៀក (រស់) ម្តាយឈ្មោះ [redacted]លៀប (រស់) កម្រិតវប្បធម៌ ថ្នាក់ទី៦ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩៧៨ ត-ព្រ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ។

-ជាប់ចោទពីបទ " រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិឈូងត្រដក់ ឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ។

២-ឈ្មោះ [redacted] ហេង ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅភូមិ[redacted] ខេត្តបាត់ដំបង សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ មានទីលំនៅបច្ចុប្បន្ន ភូមិ[redacted] ខេត្តបាត់ដំបង នៅលីវ ឪពុកឈ្មោះ [redacted] វឿត (រស់) ម្តាយឈ្មោះ [redacted] ហេវ (រស់) កម្រិតវប្បធម៌ ថ្នាក់ទី៨ ប្រវត្តិនៃការផ្តន្ទាទោសដោយ តុលាការ មាន ។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩៧៩ ត-ព្រ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ។



Scanned with CamScanner

-ជាប់ចោទពីបទ - រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីផ្តន្ទាទោសបទមជ្ឈិម - តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិឈូងត្រដក់ ឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ។

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហេង ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣៦៤៩ ជស-សព ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញដីកាដំណោះស្រាយលេខ ១៣១៨ ជ-ជ-ស ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ២២ ត-ព្រ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តបាត់ដំបង ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ៖

កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១០ និង ០៥ នាទីព្រឹក សមត្ថកិច្ចបានឃាត់ខ្លួនជនជាប់ចោទចំនួន ០២នាក់ ឈ្មោះ [redacted] វដ្ឋា និងឈ្មោះ [redacted] ហេង នៅចំណុចភូមិឈូងត្រដក់ ឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង ដោយបានដកហូតថ្នាំញៀនចំនួន ២ថង់ ទម្ងន់៨.៣៨ក្រាម(ទាំងសំបក) , សម្ភារៈប្រើប្រាស់គ្រឿងញៀន និងប្រាក់ចំនួន១០០,០០០(ដប់ម៉ឺន)រៀល ។ តាមការស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] វដ្ឋា បានឆ្លើយថាខ្លួនបានទិញថ្នាំញៀនពីឈ្មោះ [redacted] ហេង ក្នុងតម្លៃ ៩០០.០០០ (កៅសិបម៉ឺន) រៀល ដើម្បីយកទៅប្រើប្រាស់ និងរំលែកលក់បន្ត។ តាមការស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] ហេង បានឆ្លើយថា ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ សាន ក្នុងតម្លៃ ៦០០.០០០ (ហុកសិបម៉ឺន) រៀល យកទៅលក់បន្តឱ្យឈ្មោះ [redacted] វដ្ឋា ក្នុងតម្លៃ ៩០០.០០០ (កៅសិបម៉ឺន) រៀល។ ឈ្មោះ [redacted] ហេង ធ្លាប់ជាប់ពន្ធនាគារ ៦ខែ ពីបទ ប្រើប្រាស់ និងចែកចាយដោយខុសច្បាប់នូវសារធាតុញៀន ហើយទើបចេញពីពន្ធនាគារកាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ កន្លងមកនេះ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] វដ្ឋា វត្តមាន ជនជាប់ចោទឈ្មោះ [redacted] ហេង វត្តមាន ។

-ជនជាប់ចោទឈ្មោះ [redacted] វដ្ឋា បានឆ្លើយថា ៖ ខ្លួនត្រូវចាប់ខ្លួន នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ នៅផ្ទះរបស់ម្តាយខ្លួន នៅភូមិរកា ។ សមត្ថកិច្ចបានដកហូតម៉ាទឹកកក២កញ្ចប់ ទម្ងន់៧.៧៥ក្រាម ។ ចំពោះថ្នាំញៀននេះ គឺខ្លួនបានប្រើឈ្មោះ [redacted] ហេង ឱ្យទិញ ដោយពុំបានឱ្យលុយចាយទេ ។ ខ្លួនទិញយកមកដើម្បីប្រើប្រាស់ ។ ពីមុនខ្លួនទិញខ្លួនឯង តែទើបតែប្រើឈ្មោះ [redacted] ហេង ទិញម្តង ។ ខ្លួនត្រូវចាប់ខ្លួនបានជាង១ម៉ោង ទើបចាប់ឈ្មោះ [redacted] ហេង បានតាមក្រោយ ។

-ជនជាប់ចោទឈ្មោះ [redacted] ហេង បានឆ្លើយថា ៖ ចម្លើយរបស់ឈ្មោះ [redacted] វដ្ឋា ត្រឹមត្រូវ ។ ឈ្មោះ [redacted] វដ្ឋា បានប្រើខ្លួនឱ្យទិញថ្នាំញៀនឱ្យបានម្តង ទិញពីឈ្មោះ សាន នៅស្តៅ ទិញថ្នាំញៀនម៉ាទឹកកក តំលៃ១០ម៉ឺនរៀល ។ ខ្លួនត្រូវចាប់ខ្លួន ដោយពុំបានដកហូតអ្វីទេ ដោយថ្នាំញៀននោះ ខ្លួនបានប្រគល់ឱ្យ ឈ្មោះ [redacted] វដ្ឋា អស់ហើយ ។ ខ្លួនយល់ថា សមត្ថកិច្ចចាប់ខ្លួនគឺត្រឹមត្រូវហើយ ។ ខ្លួនជាប់ពន្ធនាគារ [illegible] ៦ខែ ដោយសារ [illegible] គ្រឿងញៀន ។ ខ្លួន មិនដែល



Scanned with CamScanner

ជួញដូរថ្នាំញៀនទេ ។ ខ្លួនជាកូនទោលនៅក្នុងក្រុមគ្រួសារ ហើយឪពុកម្តាយរបស់ខ្លួន មាន វ័យចំណាស់ហើយ ពុំអាចមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការរកស៊ីចិញ្ចឹមគ្រួសារ ឡើយ ជាពិសេសឪពុករបស់ខ្លួនជាយោធិនពិការ ។

-ឈ្មោះ [redacted] ហេវ ជាឪពុករបស់ជនជាប់ចោទឈ្មោះ [redacted] ហេង បានឆ្លើយថា ៖ ខ្លួនជាយោធិនពិការ ។ សព្វថ្ងៃគឺមានតែកូនប្រពន្ធនិងកូនរបស់ខ្លួន នេះឯង ដែលរកស៊ីចិញ្ចឹមខ្លួន ។ ខ្លួនស្នើសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន ហើយខ្លួននឹងណែនាំកូនឱ្យកែប្រែខ្លួន ឡើងវិញ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន ៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការរួចមក ឃើញថា ពិតជាមានអង្គហេតុដូចការចោទប្រកាន់ មែន ។ ដូច្នេះតំណាងអយ្យការស្នើសុំតម្កល់បទចោទប្រកាន់ទុកនៅជាត្រឹមត្រូវដដែល និងស្នើសុំឱ្យ ចៅក្រមជំនុំជម្រះ ផ្តន្ទាទោសជនជាប់ចោទទាំងអស់ តាមផ្លូវច្បាប់ ។

-មេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋាន ៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការ រួចមកឃើញថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] ហេង ពុំមានមែនជាអ្នកជួញដូរគ្រឿងញៀន ឡើយ គឺខ្លួនគ្រាន់តែត្រូវបានឈ្មោះ [redacted] រដ្ឋា ពឹងពាក់ឱ្យជួយទិញថ្នាំញៀន យកមកប្រើប្រាស់តែប៉ុណ្ណោះ ។ ជនជាប់ចោទជាកូនទោលក្នុងគ្រួសារ ត្រូវទទួលបន្ទុកចិញ្ចឹមឪពុកម្តាយដែលមានវ័យចំណាស់ ជាពិសេស គឺឪពុកដែលជាយោធិនពិការ ពុំមានលទ្ធភាពក្នុងការរកស៊ីផ្គត់ផ្គង់ជីវភាពគ្រួសារ ឡើយ ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំឱ្យចៅក្រជំនុំជម្រះ ផ្តល់នូវស្ថានសម្រាលទោសដល់ជនជាប់ចោទ ដោយសេចក្តីអនុគ្រោះ ។

-ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា បាននិយាយសំដីចុងក្រោយថា ៖ ខ្លួនសំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន ។

-ជនជាប់ចោទឈ្មោះ [redacted] ហេង បាននិយាយសំដីចុងក្រោយថា ៖ ខ្លួនសំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ នៅចំណុចភូមិឈូកត្រដក់ ឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង មានករណី រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មួយបានកើតឡើង ដែលបង្កដោយបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ហេង ភេទប្រុស បានទិញថ្នាំញៀនពីឈ្មោះ សាន ហើយលក់ទៅឱ្យឈ្មោះ [redacted] រដ្ឋា ក្នុងតម្លៃ៨០ម៉ឺនរៀល ដើម្បីលក់បន្ត ពិតប្រាកដមែន ។



Scanned with CamScanner

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា នៅសមត្ថកិច្ច នៅអយ្យការ និងនៅចៅក្រមស៊ើបសួរ មានន័យប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ [redacted] ហេង ពិតប្រាកដមែន ដោយខ្លួនទិញក្នុងតម្លៃ៩០ម៉ឺនរៀល គឺដើម្បីទុកសម្រាប់ប្រើប្រាស់ និងលក់ចែកចាយបន្ត។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហេង នៅសមត្ថកិច្ច នៅអយ្យការ និងនៅចៅក្រមស៊ើបសួរ មានន័យប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ សាន ក្នុងតម្លៃ៦០ម៉ឺនរៀល ទុកសម្រាប់លក់បន្ត ហើយបានលក់ឱ្យឈ្មោះ ធៀក រដ្ឋា ក្នុងតម្លៃ៩០ម៉ឺនរៀល ហើយខ្លួនក៏ធ្លាប់ជាប់ពន្ធនាគាររយពេល០៦ខែ ពីបទ ប្រើប្រាស់ និងចែកចាយដោយខុសច្បាប់នូវសារធាតុញៀន ។

-ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ជនជាប់ចោទឈ្មោះ [redacted] ហេង មានភាពស៊ីសង្វាក់ទៅនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងលទ្ធផលនៃការស៊ើបសួរ ដែលអាចកំណត់បានថា ៖ ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ពិតជាបានប្រព្រឹត្តអំពើ “រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន” តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិឈ្លូងត្រដក់ ឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ និងជនជាប់ចោទឈ្មោះ[redacted]ហេង ពិតជាបានប្រព្រឹត្តអំពើ “រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីផ្តន្ទាទោសបទមជ្ឈិម” តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិឈ្លូងត្រដក់ ឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ប្រាកដមែន ។

-តាមកំណត់ហេតុទទួលវត្ថុតាង លេខ ៥១៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ របស់អយ្យការ អមសាលាដំបូងខេត្តបាត់ដំបង ឃើញមាន ៖

១-ថ្នាំញៀនច្រកក្នុងស្រោមសំបុត្របិតជិត ចំនួន០១កញ្ចប់ ។

២-ប្រាក់រៀលចំនួន១០ម៉ឺនរៀល ។

-តាមកំណត់ហេតុ រាប់ ថ្លឹង និងដកសំណាកគ្រឿងញៀន ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ ឃើញមាន ៖ ថ្នាំញៀនប្រភេទ **មេតំហ្វេតាមីន** (ហៅក្រៅម៉ាទឹកកក ឬ អាយ) ពណ៌ស ចំនួន០២កញ្ចប់ មានទម្ងន់សាច់ថ្នាំសុទ្ធ**៧.៧៥**ក្រាម ដកសំណាកទម្ងន់សាច់ថ្នាំសុទ្ធ **១.៧៧**ក្រាម នៅសល់ក្នុងសំណុំរឿង ទម្ងន់សាច់ថ្នាំសុទ្ធ **៥.៩៨** ក្រាម ជារបស់ជនជាប់ចោទឈ្មោះ **ធៀក រដ្ឋា** ។

-តាមកំណត់ហេតុធ្វើតេស្ត និងវេចខ្ចប់វត្ថុតាង លេខ ២៩៤/២០កណហ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បានបញ្ជាក់ថា ៖ សំណាក មានសារធាតុញៀនប្រភេទ **មេតំហ្វេតាមីន** (ពណ៌ទឹកក្រូច) ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-អំពើរបស់ជនជាប់ចោទដែលបានលក់ និងទិញដើម្បីលក់គ្រឿងញៀនដោយគ្មានការអនុញ្ញាត ជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌ ពីបទ រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

-អំពើរបស់ជនជាប់ចោទ ស្តែងចេញពីចេតនាទុច្ចរិត ដោយដឹងថា អំពើលក់គ្រឿងញៀនជាអំពើខុសច្បាប់ តែពួកខ្លួននៅតែប្រព្រឹត្ត ដោយមានចេតនាបំពានលើច្បាប់ ។

-ជនជាប់ចោទខាងលើ ជានីតិជន និងជាសមត្ថជនដែលអាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម និងច្បាប់របស់រដ្ឋ ។

-មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើ ៖ ឈ្មោះ [redacted] វង្ឃា ភេទប្រុស អាយុ២៤ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ពីបទ " រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិឈូងត្រដក់ ឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ។

-មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើ ៖ ឈ្មោះ [redacted] ហេង ភេទប្រុស អាយុ២៦ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ពីបទ " រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីផ្តន្ទាទោសបទមជ្ឈិម " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិឈូងត្រដក់ ឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ។

-ជនជាប់ចោទឈ្មោះ [redacted] ហេង ជាកូនទោលនៅក្នុងគ្រួសារ ហើយត្រូវទទួលបន្ទុករកស៊ីចិញ្ចឹម មើលថែឪពុកម្តាយ ដែលមានវ័យចំណាស់ ជាពិសេស គឺឪពុកដែលជាយោធិនពិការ ពុំមានលទ្ធភាពក្នុងការរស៊ីផ្គត់ផ្គង់ជីវភាពគ្រួសារ ដូច្នេះគប្បីតុលាការ ផ្តល់នូវស្ថានសម្រាលទោសដល់ ជនជាប់ចោទរូបនេះ តាមមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសដាក់ពន្ធនាគារលើ ៖ ឈ្មោះ [redacted] វង្ឃា ភេទប្រុស អាយុ២៤ឆ្នាំ (មានសាវតារជាតិដូចខាងលើ) កំណត់រយៈពេល ៣ឆ្នាំ(បីឆ្នាំ) គិតចាប់ពីថ្ងៃឃុំខ្លួនបណ្តោះអាសន្ន និងពិន័យជាប្រាក់ចំនួន៨,០០០,០០០រៀល(ប្រាំបីលានរៀល) បង់ចូលជាថវិការដ្ឋ ពីបទ " រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិឈូងត្រដក់ ឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ។

២-ផ្តន្ទាទោសដាក់ពន្ធនាគារលើ ៖ ឈ្មោះ [redacted] ហេង ភេទប្រុស អាយុ២៦ឆ្នាំ (មានសាវតារជាតិដូចខាងលើ) កំណត់រយៈពេល ២ឆ្នាំ(ពីរឆ្នាំ) គិតចាប់ពីថ្ងៃឃុំខ្លួនបណ្តោះអាសន្ន និងពិន័យជាប្រាក់ចំនួន៤,០០០,០០០រៀល(បួនលានរៀល) បង់ចូលជាថវិការដ្ឋ ពីបទ " រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីផ្តន្ទាទោសបទមជ្ឈិម " តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិឈូងត្រដក់ ឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ និងមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

៣-វត្ថុតាង(ដូចក្នុងកំណត់ហេតុទទួលវត្ថុតាង លេខ ៥១៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តបាត់ដំបង) រួមមាន ៖ ថ្នាំញៀនប្រចក្នុងស្រោមសំបុត្របិតជិត ចំនួន០១កញ្ចប់ ត្រូវរឹបអូសយកទៅបំផ្លាញចោល និងលុយរៀលចំនួន១០០,០០០រៀល ត្រូវរឹបអូសចូលជាសម្បត្តិរដ្ឋ ។

៤-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ ត្រូវនឹងថ្ងៃពុធ ១៥រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព-ស ២៥៦៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ ត្រូវនឹងថ្ងៃចច័ន្ទ ៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព-ស ២៥៦៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រដ្ឋា និងជនជាប់ចោទឈ្មោះ [redacted] ហេង ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ តាមការកំណត់នៃច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និង ត្រា** [redacted]

**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និង ត្រា** [redacted]

---

**បានចម្លងត្រឹមត្រូវចេញពីសាលក្រមដើម**
**ថ្ងៃច័ន្ទ ៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព-ស២៥៦៤**
**បាត់ដំបង,ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១**
**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner